ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សមាសព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ ១៧៩

ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩

សាលដីកា

លេខៈ ៤៥ "V"

ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.លោក [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រមរបាយការណ៍

៤.លោក [redacted] ចៅក្រម

៥.លោក [redacted] ចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ២១៨ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ផល្លី ចំពោះសាលដីកាព្រហ្មទណ្ឌលេខ៥៦ ក្រV "វ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

**ជនជាប់ចោទ** ឈ្មោះ [redacted] ផល្លី ភេទប្រុស អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិគោកមន ឃុំដំដែក ស្រុកសូត្រនិគម ខេត្តសៀមរាប ទីលំនៅសព្វថ្ងៃស្នាក់នៅផ្ទះលេខ [redacted] រាជធានីភ្នំពេញ មុខរបរអាជីវករ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] (រ) មានកូនចំនួន០៣ នាក់ ជានីតិជន ទោសពីមុនគ្មាន។ (អ្នកប្តឹងសាទុក្ខ)

Scanned with CamScanner

-មានមេធាវីការពារសិទ្ធិលោក [redacted] ស៊ុំខឿន

**-ជាប់ចោទពីបទ៖** ឆបោក ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ នៅក្នុងអំឡុងឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា៣៧៧ និង៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

**-ដើមបណ្ដឹងរដ្ឋប្បវេណី**

**ឈ្មោះ** [redacted] ទ្រី ភេទប្រុស អាយុ៥៩ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរពាណិជ្ជករ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] រាជធានីភ្នំពេញ ។

-មានមេធាវីការពារសិទ្ធិលោក [redacted] ធារិន

**អំពីអង្គហេតុ៖**

កាលពីអំឡុងឆ្នាំ២០១២ ឈ្មោះ [redacted] ផល្លី ភេទប្រុស អាយុ៤៩ ឆ្នាំ បានមកលួងលោមឈ្មោះ [redacted] ទ្រី ភេទប្រុស អាយុ៥៩ឆ្នាំ ឱ្យមកទិញក្រុមហ៊ុនរបស់គាត់ឈ្មោះ ក្រុមហ៊ុនវឌ្ឍពេជ្រ អ៊ីម ផតអ៊ិចផត ខូ.អិល.ធី.ឌី និងឡានចំនួន៣៥គ្រឿង ក្នុងតម្លៃ ២៥.០០០$ (ពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ក្នុងមួយគ្រឿង សរុបទឹកប្រាក់ចំនួន ៨៧៥,០០០$ (ប៉ែតសិបប្រាំពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក)។ ដោយសារតែកលល្បិចនិងភាពលួងលោមរបស់ឈ្មោះ [redacted] ផល្លី ធ្វើឱ្យឈ្មោះ [redacted] ទ្រី ជឿជាក់និងទុកចិត្តក៏សម្រេចចិត្តរួចធ្វើលិខិតប្រាក់ទូទាត់ដៃចំនួន១៩៦,៨៨៨,០០$ (មួយសែនប្រាំបួនម៉ឺនប្រាំមួយពាន់ប្រាំបីរយប៉ែតសិបប្រាំបីដុល្លារអាមេរិក) ឲ្យទៅឈ្មោះ [redacted] ផល្លី លុះនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១២ ឈ្មោះ [redacted] ទ្រី និងឈ្មោះ [redacted] ផល្លី បានចុះកិច្ចសន្យាទិញក្រុមហ៊ុន និងឡានដោយប្រគល់ប្រាក់គ្រប់ចំនួន និងបានប្រគល់រថយន្តគ្រប់ចំនួនហើយដែរ។ បន្ទាប់ពីប្រគល់ទទួលរថយន្តចំនួន៣៥គ្រឿងរួចមក ឈ្មោះ [redacted] ទ្រី បានទាមទារឲ្យឈ្មោះ [redacted] ផល្លី ប្រគល់ប័ណ្ណសំគាល់យានយន្តច្បាប់ដើម (កាតគ្រី) ប៉ុន្តែឈ្មោះ [redacted] ផល្លី តែងតែគេចវេសដោយភូតកុហកថាជាប់រវល់អញ្ចេះជាប់រវល់អញ្ចោះយកលេសនេះ យកលេសនោះរហូត។ ស្រាប់តែនៅក្នុងអំឡុងឆ្នាំ២០១៤ មានតតិយជនមករឹបអូសរថយន្តដែលឈ្មោះ [redacted] ផល្លី បានយកមកលក់ឲ្យឈ្មោះ [redacted] ទ្រី ចំនួន២៦គ្រឿង ដែលអះអាងថាឈ្មោះ [redacted] ផល្លី បានយកកាតគ្រីរថយន្តទាំង២៦គ្រឿងនេះ ដាក់បញ្ចាំឲ្យពួកគេជាយូរឆ្នាំមកហើយ មិនដែលបង់ការប្រាក់ និងប្រាក់ដើមឡើយ ហើយត្រូវដាច់ទៀតផង ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៣៥០៥ “ម” ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ៖

១-ផ្ដន្ទាទោសឈ្មោះ [redacted] ផល្លី ដាក់ពន្ធនាគារកំណត់រយៈពេល០១ (មួយ) ឆ្នាំ និង០៦ (ប្រាំមួយ)ខែ ពីបទ ឆបោក ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ នៅក្នុងអំឡុងឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ផល្លី សងប្រាក់ដើមចំនួន ៦៥០.០០០$ (ហុកសិបប្រាំម៉ឺន) ដុល្លារអាមេរិក ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទ្រី ។

៣-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ផល្លី សងសំណងការខូចខាតចំនួន ៥០.០០០$ (ប្រាំម៉ឺន) ដុល្លារអាមេរិក ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទ្រី ។

៤-បង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ផល្លី ដើម្បីយកមកអនុវត្តទោស តាមអំណាចនៃសាលក្រមនេះ ស្របតាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ និងបន្តនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែកំបាំងមុខជនជាប់ចោទ ។

គូភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់បានកំណត់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ៨៤៧ ចុះថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ផល្លី ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៥០៥ “ម” ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌ៥៦ក្រ V “វ” ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ របស់ពិរុទ្ធជនឈ្មោះ [redacted] ផល្លី ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគិតច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៣៥០៥ “ម” ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ កំបាំងមុខពិរុទ្ធជនតែចាត់ទុកជាចំពោះមុខ ចំពោះមុខមេធាវីការពារសិទ្ធិឲ្យពិរុទ្ធជន,ដើមបណ្តឹងរដ្ឋប្បវេណី,មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩។

បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខ ២១៨ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ផល្លី ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាសាលាឧទ្ធរណ៍លេខ ៥៦ក្រ V “វ” ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០១៩ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។



Scanned with CamScanner

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្ដីសន្និដ្ឋានថា៖ ជនជាប់ចោទឈ្មោះ [redacted] ផល្លី ពិតជាបានលក់ក្រុមហ៊ុន វណ្ណនពេជ្រ អ៊ីមផត អិចផត ខូអិលធីឌី និងឡានចំនួន៣៥ គ្រឿង សរុបតម្លៃ ៨៧៥ ០០០ (ប្រាំបីសែនប្រាំពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ប្រគល់ប្រាក់ទូទាត់ដៃចំនួន ១៩៦ ៨៨៨ (មួយសែនប្រាំបួនម៉ឺនប្រាំមួយពាន់ប្រាំបីរយប៉ែតសិបប្រាំបី)ដុល្លារអាមេរិក ហើយបានប្រគល់ប្រាក់គ្រប់ចំនួននៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១២។ បណ្ណសំគាល់រថយន្ត (កាតគ្រី) ៣៥គ្រឿង ឈ្មោះ [redacted] ផល្លី ពុំបានប្រគល់ឱ្យមកឈ្មោះ [redacted] ទ្រី ដោយយកលេសគេចវេសរហូត។ ស្រាប់តែនៅក្នុងឆ្នាំ២០១៤ មានតតីយជនរឹបអូសរថយន្តចំនួន២៦ គ្រឿង (មានកាតគ្រីត្រឹមត្រូវ) ដោយបានបញ្ជាក់ថា រថយន្តទាំងនោះឈ្មោះ [redacted] ផល្លី បញ្ចាំឱ្យពួកគេយូរឆ្នាំហើយ។ អំពើប្រព្រឹត្តរបស់ឈ្មោះ [redacted] ផល្លី ជាបទល្មើស ឆបោក ដែលច្បាប់បញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។ សាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះ ត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការ។

**តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖**

-តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ៥៦ ក្រV "វ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ។

លោក [redacted] ស៊ីឡឿន មេធាវីការពារជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្នុងអំឡុងខែឧសភា ឆ្នាំ២០១២ កូនក្ដីខ្ញុំបាទឈ្មោះ [redacted] ផល្លី និងឈ្មោះ [redacted] ទ្រី បានព្រមព្រៀងគ្នាដាក់ហ៊ុនរកស៊ីដឹកជញ្ជូនចូលគ្នា ហើយកូនក្ដីខ្លួនមានឡានដឹកដី៣០គ្រឿង ខាង [redacted] ទ្រី មានឡានដឹក៥គ្រឿងនិងទ្រព្យផ្សេងទៀត ចាប់ផ្ដើមរកស៊ីដឹកជញ្ជូនជាមួយគ្នាតាំងពីខែឧសភា ឆ្នាំ២០១២ រហូតដល់ខែកុម្ភៈ ឆ្នាំ២០១៤ ទើបមានបញ្ហាវិវាទឈប់រកស៊ីជាមួយគ្នា។ ពាក់ព័ន្ធនិងលិខិតទិញលក់ក្រុមហ៊ុន និងរថយន្ត៣៥គ្រឿង កូនក្ដីខ្ញុំពិតជាធ្វើទៅតាមការសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អោយធ្វើលិខិតនេះ ដើម្បីយកទៅខ្ចីលុយពីធនាគារតៃវ៉ាន់មួយ។ អស់រយៈពេលប្រមាណជាជាង០៤ឆ្នាំ កន្លងមកស្រាប់តែឈ្មោះ [redacted] ទ្រី បែរជាបានមកប្ដឹងចោទប្រកាន់កូនក្ដីខ្លួនបាទពីបទ ឆបោក ដោយបានក្លែងបំភាន់ និងភូតកុហកតុលាការថា ខ្លួន ចាញ់បោកឈ្មោះ [redacted] ផល្លី ហើយបានមកទិញក្រុមហ៊ុន និងឡាន៣៥គ្រឿង ដោយបានយក លិខិតទទួលប្រាក់ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០១២ ថាជាប្រាក់ទូទាត់ដៃចំនួន១៩៦,៨៨៨$ និងលិខិតលក់ក្រុមហ៊ុន និងលក់ឡានផ្ដាច់ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១២ លក់ឡាន៣៥គ្រឿង ដោយអះអាងថា បានប្រគល់ប្រាក់គ្រប់ចំនួនទៅឱ្យកូនក្ដីខ្លួន ដែលគ្មានអ្វីជាមូលដ្ឋានត្រឹមត្រូវឡើយ។ លិខិតលក់ក្រុមហ៊ុន និងលក់ឡានផ្ដាច់ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១២ លិខិតនេះត្រូវបានធ្វើឡើង ក្នុងគោលបំណងតែមួយគត់ ដើម្បីជួយឱ្យដើមបណ្ដឹងអាចទៅខ្ចីប្រាក់ពីធនាគារតៃវ៉ាន់ មកបង្កើតភាគហ៊ុនរបស់គាត់ និងពង្រីកទុនអាជីវកម្មរួមគ្នា តែប៉ុណ្ណោះ។

Scanned with CamScanner

សំណូមពរ សូមឱ្យប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការកំពូល សម្រេចបដិសេធសាលដីកាសាលាឧទ្ធរណ៍។ និងសុំបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍។ សុំឱ្យតុលាការមេត្តាអនុញ្ញាតឱ្យកូនក្តីខ្ញុំ បាននៅក្រៅឃុំជាបណ្តោះអាសន្ន។

លោក [redacted] ធារិន ជាមេធាវីការពារដើមបណ្តឹងធ្វើសេចក្តីសន្និដ្ឋានថា៖ យើងមានឯកសារគ្រប់គ្រាន់នឹងពិតប្រាកដ ឈ្មោះ [redacted] ផល្លី មិនព្រមទទួលស្គាល់កំហុសរបស់ខ្លួនបែរជាប្រឌិតអង្គហេតុផ្សេងៗ ក្នុងគោលបំណងគេចវេសពីសំណាញ់ច្បាប់ និងមិនចង់ទទួលខុសត្រូវចំពោះសំណងរដ្ឋប្បវេណីតាមអំណាចសាលក្រមសាលាដំបូង និងសាលដីកាសាលាឧទ្ធរណ៍ជាដើម។

សំណូមពរៈ ស្នើសុំក្រុមប្រឹក្សាច្រានចោលបណ្តឹងសាទុក្ខ និងសុំតម្កល់សាលដីកាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ទុកជាបានការដដែល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២១៨ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ផល្លី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ សម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ៣៥០៥ "ម" ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែលនោះជាការត្រឹមត្រូវ ហើយពីព្រោះថា ជនជាប់ចោទឈ្មោះ [redacted] ផល្លី ពិតជាបានលក់ ក្រុមហ៊ុន វឌ្ឍពេជ្រ អឹមផត អ៊ិចផត ខូ.អិល.ធី.ឌី និងឡានចំនួន៣៥គ្រឿង ហើយជនជាប់ចោទបានទទួលប្រាក់គ្រប់ចំនួនពីដើមបណ្តឹងរដ្ឋប្បវេណី។ ប៉ុន្តែប័ណ្ណសំគាល់រថយន្ត (កាតគ្រី) ជនជាប់ចោទឈ្មោះ [redacted] ផល្លី ពុំបានប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទ្រី ទេ ដោយរកលេសគេចវេសរហូត។ លុះក្នុងអំឡុងឆ្នាំ២០១៤ មានតតីយជនមករឹបអូសរថយន្ត ដែលជនជាប់ចោទបានលក់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី (មានកាតគ្រីត្រឹមត្រូវ) ដោយបានបញ្ជាក់ថា រថយន្តទាំងអស់នោះ ជនជាប់ចោទឈ្មោះ [redacted] ផល្លី បានយកមានបញ្ចាំពួកគេយូរឆ្នាំហើយ។ ដូច្នេះ អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ផល្លី ជាបទល្មើស ឆបោក ដែលច្បាប់បញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

៣-យល់ឃើញថា នាពេលសវនាការ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ សុំឱ្យតុលាការកំពូលពន្យារពេលសវនាការ ដោយមូលហេតុថាកូនក្តីខ្លួន មានជម្ងឺនោះ តុលាការកំពូល យល់ឃើញថា ថ្វីត្បិតតែ ជនជាប់ចោទមានជម្ងឺក៏ដោយ ប៉ុន្តែ នាពេលនេះតុលាការកំពូល ជំនុំជម្រះតែអង្គច្បាប់ ហើយជនជាប់ចោទក៏បានដាក់សារណាការពារជូនមកតុលាការកំពូលរួចហើយ ហើយលោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទក៏មានវត្តមាន ដូច្នេះ អនុលោមតាមមាត្រា៤៣៤ និង៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចបន្តនីតិវិធីជំនុំជម្រះរឿងក្តីនេះបាន។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៥៦ ក្រV “វ” ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមគតិច្បាប់។

**ហេតុដូច្នេះ**

**សម្រេច**

១-បដិសេធ បណ្តឹងសាទុក្ខលេខ២១៨ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ផល្លី។

២-តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ៥៦ ក្រ V “វ” ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

Scanned with CamScanner